# បានសង្គ្រោះចេញពីភក់



**ដោយអែលឌើរ អាឌីលសុន**
**ឌី ប៉ោឡា ផារ៉ែលឡា**
ក្នុងពួកចិតសិបនាក់

« *ខ្ញុំចែកក្ដីស្នេហ៍ព្រះគ្រីស្ទ តាមការបម្រើអ្នកដទៃ* » ( សៀវភៅចម្រៀងកុមារ *លេខ ៤២* ) ។

គ្រួសារខ្ញុំបានរស់នៅទីក្រុង សៅ ផាឡូ ប្រទេសប្រេស៊ីល ។ នៅត្រើយម្ខាងទៀតនៃផ្លូវរបស់យើង មានព្រៃកោងកាងមួយ ។ ព្រៃកោងកាងមានទន្លេហូរកាត់ព្រៃនោះ ។ បាតខាងក្រោមនោះសុទ្ធតែជាភក់ ។

មនុស្សជាច្រើនបានសង់ផ្ទះនៅលើដីភក់នោះ ។ ពួកគេដាក់ឈើធំៗទៅក្នុងភក់ ។ បន្ទាប់មក ពួកគេបានសាងសង់ផ្ទះរបស់ពួកគេនៅផ្នែកខាងលើនៃឈើទាំងនោះ ។ ប៉ុន្តែពេលភ្លៀង ទឹកទន្លេបានជន់ឡើង ។ ទឹកនោះបានហូរចូលផ្ទះរបស់ពួកគេ ។ បន្ទាប់មកប្រជាជនគ្មានកន្លែងដេកនៅពេលយប់ទេ ។

នៅពេលមានរឿងនោះកើតឡើង ឪពុករបស់ខ្ញុំនឹងអញ្ជើញពួកគេទាំងអស់គ្នាមកក្នុងផ្ទះរបស់យើង ។ ជួនកាល មានមនុស្សដល់ទៅ ១៥ នាក់ ! គាត់បាននាំពួកគេទៅក្នុងបន្ទប់ទទួលភ្ញៀវ ហើយឲ្យភួយទៅពួកគេ ។ ម៉ាក់បានចំអិនម្ហូបឲ្យពួកគេបរិភោគ ។ បន្ទាប់មក ពួកគេបានសម្រាកនៅក្នុងផ្ទះយើង រហូតដល់ថ្ងៃបន្ទាប់ ។

រឿងនេះបានកើតឡើងយ៉ាងហោចណាស់បី ឬបួនដង ។ ខ្ញុំចាំពីការគិតថា « ពុំមានមនុស្សច្រើនទេ ដែលអនុញ្ញាតឲ្យមនុស្សមិនស្គាល់ចូលផ្ទះ » ។ ឪពុកខ្ញុំបានអនុញ្ញាតឲ្យមនុស្សដែលយើងពុំស្គាល់ដេកនៅក្នុងផ្ទះរបស់យើង ! ប៉ុន្តែក្រោយមកខ្ញុំបានគិតថា « ពួកគេគ្មានកន្លែងផ្សេងទៀតទៅឡើយ » ។

ឪពុកម្ដាយរបស់ខ្ញុំតែងធ្វើកិច្ចការដើម្បីជួយគេឯងជានិច្ច ។ ប៉ុន្តែការបម្រើរបស់ពួកគេគឺលើសពីការជួយ និងការផ្ដល់ឲ្យគេទៅទៀត ។ វាគឺជាការបង្ហាញសេចក្ដីស្រឡាញ់ដល់អ្នកជិតខាងយើង ទោះបីអ្នកជិតខាងយើងជាមនុស្សដែលយើងមិនស្គាល់ពួកគេច្បាស់ក្តី ។

យើងគួរតែឈោងទៅជួយមនុស្សដែលខ្វះខាត ។ យើងគួរតែជួយពួកគេជាមួយអ្វីគ្រប់យ៉ាងដែលយើងអាចជួយបាន ។ យើងពុំគួរមានដែនកំណត់ចំពោះអ្វីដែលយើងអាចធ្វើដើម្បីជួយមនុស្សទេ ។ យើងអាចផ្ដល់ជម្រក និងធនធានដល់ពួកគេ ។ យើងអាចចែករំលែកពេលវេលាជាមួយពួកគេ ។ យើងអាចចែកចាយចំណេះដឹងយើងអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ជាពិសេសនៅរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ ។ ■

